សាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ

UNIVERSITY OF PUTHISASTRA

# Maternal Health Nursing1

Presented by

Mrs. Ngim HENG, BSN, RM, NMCHC

Tel: 012 649 251

Email: hengngim@yahoo.com

# ភាពដឹកនាំ និងគ្រប់គ្រងទី២

| ចំណងជើងមេរៀន | ម៉ោង |
|---|---|
| ១. ភាពជាអ្នកដឹកនាំ | ៣ម៉ោង |
| ២. ភាពជំរុញលើកទឹកចិត្ត | ៤ម៉ោង |
| Mid-term | |
| ៣. ការគ្រប់គ្រងទំនាស់ | ៣ម៉ោង |
| ៤. ការវិភាគពីរចនាសម្ពន្ធ័ និងគ្រឹះស្ថានព្យាបាល | ៥ម៉ោង |




# ភាពដឹកនាំ និង គ្រប់គ្រងទី២

បង្ហាញដោយលោកស្រី ហេង ងឹម
BSN, RM, NMCHC, MOH

# មេរៀនទី១

# ភាពជាអ្នកដឹកនាំ

# ទស្សនៈ

នៅចុងបញ្ចប់នៃមេរៀននេះនិស្សិតទាំងអស់នឹងអាច

1.កំណត់ន័យ**<u>អ្នកដឹកនាំ</u>**

2.ពន្យល់ពី**<u>ភាពខុសគ្នា</u>**រវាង**<u>អ្នកដឹកនាំ</u>**និង**<u>អ្នកគ្រប់គ្រង</u>**

3.រៀបរាប់ពី**<u>ចរិកលក្ខណៈ</u>** និង**<u>លក្ខណៈនៃអ្នកដឹកនាំ</u>**

4.រៀបរាប់ពីមុខងារគន្លឹះ និងភារកិច្ចជាមូលដ្ឋាននៃ**<u>អ្នកដឹកនាំល្អ</u>**

# សេចក្តីផ្តើម

នៅក្នុងអង្គភាពណាក៏ដោយគឺត្រូវមានអ្នកដឹកនាំ ព្រោះអ្នកដឹកនាំមានសារៈសំខាន់ណាស់។ បើគ្មានអ្នកដឹកនាំទេគឺ៖

១. អាចគ្មានទិសដៅដើម្បីឈានទៅដល់គោលដៅរបស់អង្គភាពឡើយ

២. អាចគ្មានអ្នកធ្វើផែនការ

៣. មិនអាចអនុវត្តអោយបានត្រឹមត្រូវនូវសកម្មភាពផ្សេងៗ

៤. មិនអាចមានភាពច្បាស់លាស់អំពីតំលៃគោលដៅ និងវត្ថុបំណង

# និយមន័យ អ្នកដឹកនាំ

- អ្នកដឹកនាំ គឺជាមនុស្សម្នាក់ដែលមានសមត្ថភាព មានឥទ្ធិពល ឬជំរុញអោយមានអ្នកឯទៀតធ្វើតាមខ្លួន។


smarp
Management Vs. Leadership
Leaders
Set the vision
Think ideas
Inspire people
Look in the future
Shape the culture
while
Managers
Follow the vision
Think execution
Drive people's success
Work in the present
Endorse the culture
smarp

# ភាពខុសគ្នារវាងអ្នកដឹកនាំ និងអ្នកគ្រប់គ្រង

អ្នកដឹកនាំ៖

- រុញច្រានរបៀបប្រតិបត្តិការអោយរីកចម្រើន ដោយណែនាំទិសដៅក្នុងការកែប្រែ ឬផ្លាស់ប្តូរ
- ធ្វើការប្រថុយដោយត្រិះរិះពិចារណា
- កំណត់គោលដៅប្រកបដោយមហិច្ឆតាគិតទៅអនាគត

អ្នកគ្រប់គ្រង៖

- ការពាររបៀបប្រតិបត្តិការ ដោយរក្សាតាមប្រព័ន្ធបច្ចុប្បន្ន
- កាត់បន្ថយការប្រថុយប្រថាន
- កំណត់គោលដៅសមស្រប

# ភាពខុសគ្នារវាងអ្នកដឹកនាំ និងអ្នកគ្រប់គ្រង (ត)

អ្នកដឹកនាំ៖

- គិតទៅអនាគតកាល និងបង្កើតទស្សនៈវិស័យសម្រាប់អនាគតកាល
- ខិតខំបង្កើតអោយមានបរិយាកាសការងារគួរអោយរំភើបចិត្ត

អ្នកគ្រប់គ្រង៖

- គិតអំពីកង្វល់ចំពោះមុខ និងខ្វល់ខ្វាយក្នុងប្រតិបត្តិការប្រចាំថ្ងៃ
- ខិតខំ ដើម្បីអោយមានបរិយាកាសការងារងាយស្រួល

# ភាពខុសគ្នារវាងអ្នកដឹកនាំ និងអ្នកគ្រប់គ្រង (ត)

អ្នកដឹកនាំ៖

- គិតគូពីការបង្កើតថ្មី
- គិតគូរដល់ការច្នៃប្រឌិត
- ផ្ទេរអំណាចដល់អ្នកដទៃ

-មានជំនឿលើបុគ្គលិក

-ស្វែងរកអ្នកដែលអាចក្លាយជាអ្នកដឹកនាំ

-ជំរុញបុគ្គលិកឱ្យកាន់តែខិតខំប្រឹងប្រែងក្នុងការងារ

- អ្នកធ្វើការងារទុកដូចជាអ្នកអនុវត្តតាម

-មានជំនឿលើក្រុមការងារ

អ្នកគ្រប់គ្រង៖

- គិតគូរដល់ការទទួលខុសត្រូវប្រចាំថ្ងៃ
- ផ្ទេរអំណាចអោយអ្នកដទៃដោយប្រុងប្រយ័ត្ន

-អ្នកធ្វើការជានិយោជិក

-ជឿជាក់លើប្រព័ន្ធ (រចនាសម្ព័នចាត់តាំង និងដំណើរការការងារ)

# ភាពខុសគ្នារវាងអ្នកដឹកនាំ និងអ្នកគ្រប់គ្រង (ត)

អ្នកដឹកនាំ៖

- ប្រើអំណាចដោយស្វាហាប់
- ជំរុញទឹកចិត្តអ្នកក្រោមឱវាទអោយធ្វើសកម្មភាព

អ្នកគ្រប់គ្រង៖

- ប្រើអំណាចដោយប្រុងប្រយ័ត្ន និងធ្វើប្រតិបត្តិការក្នុងរង្វង់ឋានុក្រម
- ត្រួតពិនិត្យអ្នកក្រោមឱវាទ


LET'S DO IT!
GO AND DO IT!
LEADER VS. MANAGER

# ចរិតលក្ខណៈ និងលក្ខណៈពិសេសនៃអ្នកដឹកនាំ

អ្នកស្រាវជ្រាវខ្លះបានសាកល្បងកំណត់ន័យ កិច្ចដឹកនាំទៅតាមលក្ខណៈពិសេសនិងចរិតលក្ខណៈ។ វិធីអោយនិយមន័យកិច្ចដឹកនាំនេះត្រូវបានសម្គាល់ថាជា «មហាបុរស» ឬជាទ្រឹស្តីអំពីលក្ខណៈពិសេសក្នុងសង្គម និងជូនកាលជាចរិតលក្ខណៈនិងលក្ខណៈនៃរូបកាយ។ គេអាចធ្វើចំណាត់ថ្នាក់ដោយផ្អែកលើជំនាញនិងសមត្ថភាព

# ចរិតលក្ខណៈនៃអ្នកដឹកនាំល្អ

- ស្លូតបូត ឬសុភាពរាបសារ
- មានសមត្ថភាព
- ស្វ័យត្រួតពិនិត្យ ឬម្ចាស់ការលើខ្លួនឯង
- ជាអ្នករៀបចំចាត់ចែង (មានជំនាញខាងធ្វើផែនការ និងចាត់ចែង)

# ចរិតលក្ខណៈនៃអ្នកដឹកនាំល្អ (ត)

- ក្លាហាន
- បង្កើតគំនិតថ្មី និងជំរុញចិត្ត (សមត្ថភាពក្នុងការដឹកនាំក្រុមការងារ និងសមត្ថភាពជំរុញទឹកចិត្តខ្លួនឯង និងអ្នកដទៃ)
- មានប្រាជ្ញា (សមត្ថភាពធ្វើអោយការងារមានប្រសិទ្ធភាព)

# ចរិតលក្ខណៈនៃអ្នកដឹកនាំល្អ (ត)

- មានចិត្តសប្បុរស
- អាកប្បកិរិយាល្អ
- អាចដោះស្រាយបញ្ហាបាន (ប្រាជ្ញាមោះមុត)
- ហ៊ានធ្វើពលិកម្ម
- ធ្វើការងារលំបាក

# ចរិតលក្ខណៈនៃអ្នកដឹកនាំល្អ (ត)

- ប្រមើលមើលទៅមុខក្នុងការងារ
- គំនិតទូលំទូលាយ
- មានប្រឌិតញាណ
- មានគំនិតទ្រទ្រង់
- ភាពចាស់ទុំ

# ចរិតលក្ខណៈនៃអ្នកដឹកនាំល្អ (ត)

- មានគំនិតប្ដេជ្ញាអនុវត្ត
- ស្មោះត្រង់
- មានគតិបណ្ឌិត (យល់ដឹង)
- ពូកែចងចាំ
- អ្នកពូកែស្ដាប់

# លក្ខណៈពិសេសនៃបុគ្គលលក្ខណៈ

- យល់ដឹងច្រើនជាងអ្នកក្រោមបង្គាប់
- សម្បូរថាមពលខាងផ្លូវកាយ
- មានសេចក្ដីសារទរ
- មានគំនិតផ្ទាល់ខ្លួន
- មានគំនិតផ្ដួចផ្ដើម

# លក្ខណៈពិសេសនៃបុគ្គលលក្ខណៈ (ត)

- ធ្វើការលំបាក
- សំរេចចិត្តលឿន និងត្រឹមត្រូវ
- មានភាពជាក់លាក់ មានជំហរច្បាស់លាស់
- ស្វិតស្វាង តស៊ូ

# លក្ខណៈពិសេសក្នុងសង្គម

- ប៉ិនប្រសប់ (មិនធ្វើអោយគេអាម៉ាស់)
- មានសណ្ដានចិត្ត
- កិត្យានុភាព
- អំណត់
- ជឿជាក់លើអ្នកដទៃ និងខ្លួនឯង (ចិត្តភក្ដី)
- មិនអួតអាង (ដាក់ខ្លួន)

# លក្ខណៈនៃរូបកាយ

- មានរូបរាងគួរអោយទាក់ទាញចិត្ត
- នឹងនរ សមរម្យ
- សុខភាពល្អ

# ជំនាញដែលអ្នកដឹកនាំល្អត្រូវមាន

- បញ្ញា មានសមត្ថភាពគិតសមហេតុផល (ជំនាញខាងការគិត)
- បំណិនទទួលរាក់ទាក់ល្អជាមួយអ្នកដទៃ (ជំនាញខាងទំនាក់ទំនងជាមួយមនុស្ស ឬអន្តរបុគ្គល)
- សមត្ថភាពបច្ចេកទេស (ជំនាញបច្ចេកទេស)

# ជំនាញដែលអ្នកដឹកនាំល្អត្រូវមាន (ត)

- សមត្ថភាពជំរុញទឹកចិត្តផ្ទាល់ខ្លួន និងអ្នកដទៃ (ជំនាញជំរុញទឹកចិត្ត)
- សមត្ថភាពប្រាស្រ័យទាក់ទងយ៉ាងសក្តិសិទ្ធ (ជំនាញប្រាស្រ័យទាក់ទង)
- អារម្មណ៍នឹងនរ និងម្ចាស់ការលើខ្លួនឯង

# ជំនាញដែលអ្នកដឹកនាំល្អត្រូវមាន (ត)

- ជំនាញខាងផែនការកម្ម និងរៀបចំចាត់ចែង
- ប្រាជ្ញាមោះមុត ក្នុងការសម្រេចភារកិច្ច
- បំណិនដឹកនាំក្រុមការងារ
- បំណិនធ្វើអោយការងារមានប្រសិទ្ធភាព
- បំណិនក្នុងការច្នៃប្រឌិត និងកែប្រែថ្មីនៅពេលដែលមានតម្រូវការ
- បំណិនដោះស្រាយភាពតានតឹង។


LEADERSHIP
VS
MANAGEMENT

# Thank You for Your Attendant